មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីប្រកាសព័ត៌មានបន្ទាន់

*រាជធានីភ្នំពេញ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៧*

## ការរឹតត្បិតសហគមន៍មិនឲ្យធ្វើដំណើរមករាជធានីភ្នំពេញដើម្បីដាក់ញត្តិជូននាយករដ្ឋមន្ត្រី និងឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុប

នៅថ្ងៃព្រហស្បតិ៍ ទី១៨ ខែឧសភា ឆ្នាំ២០១៧ សហគមន៍មួយចំនួនដែលរងផលប៉ះពាល់ដោយសារការរំលោភបំពានសិទ្ធិដីធ្លី និងការទន្ទ្រានដីធ្លីដែលកើតចេញពីការផ្តល់ដីសម្បទានសេដ្ឋកិច្ច មកពីខេត្តចំនួនបី រួមមានខេត្តកំពង់ស្ពឺ ខេត្តឧត្តរមានជ័យ និងខេត្តកោះកុង បានព្យាយាមធ្វើដំណើរមករាជធានីភ្នំពេញ ដើម្បីតាមដានញត្តិរបស់ខ្លួនដែលបានដាក់ជូនលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំប្រទេសកម្ពុជា ឯកឧត្តម ចច អេដ៍ហ្គ័រ។

ញត្តិដែលបាននោះគឺស្នើឲ្យរាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") ចុះហត្ថលេខា និងអនុម័តកិច្ចព្រមព្រៀងស្តីពីលក្ខខណ្ឌយោងរវាងប្រទេសកម្ពុជា និងសហភាពអឺរ៉ុប ដែលពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងពាណិជ្ជកម្មលើ 'គ្រប់ទំនិញទាំងអស់លើកលែងតែអាវុធ' ដើម្បីធានានូវការវាយតម្លៃឯករាជ្យអំពីការទាមទារដីធ្លីរបស់សហគមន៍ទាក់ទិននឹងក្រុមហ៊ុនចម្ការអំពៅ។ ស្ករភាគច្រើនដែលបានផលិតលើដីសម្បទានសេដ្ឋកិច្ចទាំងនោះគឺនាំចេញទៅកាន់សហភាពអឺរ៉ុប។

ទោះជាយ៉ាងនេះក្តី នៅថ្ងៃទី១៨ ខែឧសភា អាជ្ញាធរមូលដ្ឋាននៅស្រុកឱរ៉ាល់ និងថ្ពង ខេត្តកំពង់ស្ពឺ រួមទាំងអភិបាលស្រុកឱរ៉ាល់ និងកងកម្លាំងនគរបាលជាច្រើននាក់ បានរារាំងអ្នកភូមិប្រមាណជា ១៩៧ នាក់មិនឲ្យធ្វើដំណើរទៅកាន់រាជធានីភ្នំពេញ។[1] អាជ្ញាធរតម្រូវឲ្យជ្រើសរើសសមាជិកសហគមន៍ចំនួន៤ រូប ដែលអ្នកទាំង៤នេះអាចធ្វើដំណើរទៅរាជធានីភ្នំពេញក្នុងនាមជាតំណាងឲ្យសហគមន៍ទាំងអស់នោះ។ សមាជិកសហគមន៍បានយល់ព្រមធ្វើតាម ហើយតំណាងរបស់ពួកគាត់ចំនួន៤ រូបបានបន្តដំណើរយកញត្តិទៅដល់រាជធានីភ្នំពេញដោយពុំមានការរារាំងទៀតនោះទេ។ ជាសរុប សមាជិកសហគមន៍ចំនួនប្រមាណ៤៦ នាក់មកពីខេត្តកំពង់ស្ពឺ ខេត្តឧត្តរមានជ័យ និងខេត្តកោះកុង បានដាក់ញត្តិបន្ថែមរបស់ខ្លួនជូនលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំនៅកម្ពុជា ដោយជោគជ័យ។[2]

---

[1] អូន ភាព, 'នគរបាលឃាត់ក្បួនរថយន្តអ្នកភូមិមិនឱ្យធ្វើដំណើរមកដាក់ញត្តិនៅភ្នំពេញ', *ខេមបូឌា ដេលី* (ថ្ងៃទី១៩ ខែឧសភា ឆ្នាំ ២០១៧) http://www.cambodiadailykhmer.com/37502

[2] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាទទួលបានព័ត៌មាននេះពីសមាជិកសហគមន៍មួយចំនួន កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៧។

សកម្មភាពរបស់អាជ្ញាធរខេត្តកំពង់ស្ពឺ ដែលរារាំងអ្នកភូមិប្រមាណជា ១៩៧ នាក់មិនឲ្យធ្វើដំណើរមករាជធានីភ្នំពេញ ជាការរំលោភបំពានលើសិទ្ធិសេរីភាពខាងការធ្វើដំណើរ សេរីភាពខាងការប្រមូលផ្តុំ និងសេរីភាពខាងការបញ្ចេញមតិ។ សិទ្ធិទាំងនេះត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលមានអានុភាពអនុវត្តដោយផ្ទាល់នៅក្នុងច្បាប់ជាតិ។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក ឌុច ពិសិដ្ឋ នាយកផ្នែកតស៊ូមតិនៃ ម.ស.ម.ក តាមរយៈទូរស័ព្ទ៖ +៨៥៥ (០) ១២ ៧១ ២៣ ៧១ ឬ អ៊ីម៉ែល៖ duchpiseth@cchrcambodia.org៕**